ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

របាយការណ៍ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល
ប្រចាំខែមករា ឆ្នាំ២០២៣

ល.រ.	មាតិកា	ទំព័រ
១	សេចក្តីសង្ខេប	១
២	តារាងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (រដ្ឋបាលថ្នាក់ជាតិ)	២
២.១	តារាងស្ថិតិប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល	២
២.២	តារាងស្ថិតិប្រតិបត្តិការចំណូល	៣
២.៣	តារាងស្ថិតិប្រតិបត្តិការចំណាយ	៥
២.៤	តារាងស្ថិតិប្រតិបត្តិការទ្រព្យសកម្ម និងទ្រព្យអកម្ម	៦
២.៥	ក្រាហ្វិក	៧
៣	តារាងស្ថិតិប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល (សរុបថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ)	៩
៤	តារាងស្ថិតិប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល (រដ្ឋបាលថ្នាក់ជាតិ)	១០
៥	តារាងស្ថិតិប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល (រដ្ឋបាលថ្នាក់ក្រោមជាតិ)	១១
៦	ភាពខុសគ្នានៃស្ថិតិ GFS និងស្ថិតិ TOFE	១២
៧	សេចក្តីសង្ខេបអំពី "ក្របខ័ណ្ឌប្រព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល"	១៣
៨	កំណត់សម្គាល់ស្ថិតិ	១៩

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855)23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

១.សេចក្តីសង្ខេប

ក្នុងរយៈពេល ១ខែ ដើមឆ្នាំ២០២៣ ការប្រមូលចំណូលថ្នាក់ជាតិ សម្រេចបាន ១ ៨៩៨ ប៊ីលានរៀល ស្មើនឹង ៧,២៣% នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២៣ ខណៈដែលការអនុវត្តចំណាយសរុបថ្នាក់ជាតិ សម្រេចបាន ១ ០៧៥ ប៊ីលានរៀល ស្មើនឹង ៣,២៧% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៣។ ជាលទ្ធផល ការអនុវត្តថវិកាថ្នាក់ជាតិទទួលបានអតិរេកសរុប ៨២៣ ប៊ីលានរៀល។

បើធៀបនឹងរយៈពេលអនុវត្តដូចគ្នាឆ្នាំ២០២២ ការប្រមូលចំណូលសរុបថ្នាក់ជាតិ កើនឡើង ៩,៨៤% ក្នុងនោះ ចំណូលពន្ធ កើនឡើង ៧,៧៤% ចំណូលមិនមែនពន្ធ កើនឡើង ៨០,៩៣% ខណៈដែលចំណូលពីអំណោយធ្លាក់ចុះ ១០,០០%។

ការអនុវត្តចំណាយសរុបថ្នាក់ជាតិថយចុះ ២២,៤១% បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២២ ក្នុងនោះ ចំណាយមូលធនថយចុះ ៥៤,៩០% (ចំណាយដោយហិរញ្ញប្បទានក្នុងស្រុក ថយចុះ ៩៧,៩៥% ខណៈដែលចំណាយដោយហិរញ្ញប្បទានក្រៅស្រុក កើនឡើង ១៦,០៧%) រីឯចំណាយចរន្ត កើនឡើង ៨,៣១%។

រាជរដ្ឋាភិបាលបន្តពង្រឹងការគ្រប់គ្រងនិងការប្រើប្រាស់ទ្រព្យសកម្ម (assets) និងទ្រព្យអកម្ម ឬបំណុល (liabilities) ប្រកបដោយប្រសិទ្ធភាព ដើម្បីផ្តល់លទ្ធភាពគ្រប់គ្រាន់សម្រាប់ឆ្លើយតបទៅនឹងតម្រូវការចំណាយបានទាន់ពេលវេលា។ ក្នុងរយៈពេល ១ខែ ដើមឆ្នាំ ២០២៣ ទ្រព្យសុទ្ធ (net worth) របស់រដ្ឋបាលថ្នាក់ជាតិ សម្រេចបានសរុប ១ ១៨៤ ប៊ីលានរៀល (កើនឡើង ៧៥,៥៤% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២២) ដែលជាលទ្ធផលនៃការកើនឡើងទ្រព្យសកម្មប្រមាណ ១ ២៦៧ ប៊ីលានរៀល (ក្នុងនោះ ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ សរុប ៣៦១ ប៊ីលានរៀល និងទ្រព្យសកម្មហិរញ្ញវត្ថុសរុប ៩០៦ ប៊ីលានរៀល) និងការកើនឡើងបំណុល សរុប ៨២ ប៊ីលានរៀល (ថយចុះ ៣២,៨៧% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២២)។

❋❋✾❋❋

២.តារាងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (រដ្ឋបាលថ្នាក់ជាតិ) (១)

២.១.តារាងស្ថិតិប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល

ឯកតា÷ លានរៀល

		ច្បាប់ឆ្នាំ ២០២៣	អនុវត្តន៍ ឆ្នាំ២០២៣	អនុ/ច្បា ២០២៣	មករា ២៣	កុម្ភៈ ២៣	មីនា ២៣	មេសា ២៣	ឧសភា ២៣	មិថុនា ២៣	កក្កដា ២៣	សីហា ២៣	កញ្ញា ២៣	តុលា ២៣	វិច្ឆិកា ២៣	ធ្នូ ២៣
	វិធីសាស្ត្រគណនេយ្យ	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash
1	**ចំណូល**	**26,246,991**	**1,898,920**	**7.23%**	**1,898,920**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**
11	ពន្ធ	23,100,116	1,722,397	7.46%	1,722,397	0	0	0	0	0	0	0	0	0	0	0
13	អំណោយ	912,569	58,215	6.38%	58,215	0	0	0	0	0	0	0	0	0	0	0
14	ចំណូលផ្សេងៗ	2,234,306	118,308	5.30%	118,308	0	0	0	0	0	0	0	0	0	0	0
2	**ចំណាយ**	**18,748,112**	**714,316**	**3.81%**	**714,316**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**
21	បន្ទុកបុគ្គលិក	8,616,086	604,942	7.02%	604,942	0	0	0	0	0	0	0	0	0	0	0
22	ទំនិញ និងសេវាកម្ម	3,299,407	29,134	0.88%	29,134	0	0	0	0	0	0	0	0	0	0	0
24	ការប្រាក់	769,491	61,328	7.97%	61,328	0	0	0	0	0	0	0	0	0	0	0
25	ឧបត្ថម្ភធន	9,000	…	…	0	0	0	0	0	0	0	0	0	0	0	0
26	អំណោយ	2,975,375	1,209	0.04%	1,209	0	0	0	0	0	0	0	0	0	0	0
27	ឧបត្ថម្ភសង្គមកិច្ច	2,091,777	10,655	0.51%	10,655	0	0	0	0	0	0	0	0	0	0	0
28	ចំណាយផ្សេងៗ	986,976	7,048	0.71%	7,048	0	0	0	0	0	0	0	0	0	0	0
GOB	***តុល្យភាពប្រតិបត្តិការដុល***	**7,498,879**	**1,184,604**	**15.80%**	**1,184,604**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**
NOB	***តុល្យភាពប្រតិបត្តិការសុទ្ធ***	**7,498,879**	**1,184,604**	**15.80%**	**1,184,604**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**
31	**ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ**	**14,141,846**	**361,173**	**2.55%**	**361,173**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**
311	ទ្រព្យអចលត៍	14,141,846	361,173	2.55%	361,173	0	0	0	0	0	0	0	0	0	0	0
314	ទ្រព្យសកម្មគ្មានផលិតភាព	0	…	…	0	0	0	0	0	0	0	0	0	0	0	0
2M	**ចំណាយសរុប**	**32,889,958**	**1,075,489**	**3.27%**	**1,075,489**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**
NLB	***សមតុល្យនៃការផ្ដល់កម្ចី ឬទទួលកម្ចី***	**-6,642,968**	**823,431**	**…**	**823,431**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**
32	**ទ្រព្យហិរញ្ញវត្ថុសុទ្ធ**	**-1,056,500**	**906,402**	**…**	**906,402**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**
321	ក្នុងប្រទេស	-1,056,500	906,402	…	906,402	0	0	0	0	0	0	0	0	0	0	0
33	**បំណុលសុទ្ធ**	**5,586,468**	**82,971**	**1.49%**	**82,971**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**
332	ក្រៅប្រទេស	4,773,468	82,971	1.74%	82,971	0	0	0	0	0	0	0	0	0	0	0

(១). មិនរួមបញ្ចូលគ្រឹះស្ថានសាធារណៈរដ្ឋបាល

២.តារាងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (រដ្ឋបាលថ្នាក់ជាតិ) (១)

២.២.តារាងស្ថិតិប្រតិបត្តិការចំណូល

ឯកតា÷ លានរៀល

		ច្បាប់ឆ្នាំ ២០២៣	អនុវត្តន៍ ឆ្នាំ២០២៣	អនុ/ច្ប ២០២៣	មករា ២៣	កុម្ភៈ ២៣	មីនា ២៣	មេសា ២៣	ឧសភា ២៣	មិថុនា ២៣	កក្កដា ២៣	សីហា ២៣	កញ្ញា ២៣	តុលា ២៣	វិច្ឆិកា ២៣	ធ្នូ ២៣
	វិធីសាស្ត្រគណនេយ្យ	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash
1	**ចំណូល**	**26,246,991**	**1,898,920**	**7.23%**	**1,898,920**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**
11	**ពន្ធ**	**23,100,116**	**1,722,397**	**7.46%**	**1,722,397**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**
111	**ពន្ធលើប្រាក់ចំណូល និងប្រាក់ចំណេញ**	7,257,989	666,096	9.18%	666,096	0	0	0	0	0	0	0	0	0	0	0
1111	ពន្ធរូបវន្តបុគ្គល	1,357,989	147,212	10.84%	147,212	0	0	0	0	0	0	0	0	0	0	0
1112	ពន្ធនីតិបុគ្គល	5,900,000	518,884	8.79%	518,884	0	0	0	0	0	0	0	0	0	0	0
114	**ពន្ធលើទំនិញ និងសេវាប្រើប្រាស់**	13,324,905	882,419	6.62%	882,419	0	0	0	0	0	0	0	0	0	0	0
1141	ពន្ធទូទៅលើទំនិញ និងសេវាប្រើប្រាស់	7,865,355	566,382	7.20%	566,382	0	0	0	0	0	0	0	0	0	0	0
11411	អាករលើតម្លៃបន្ថែម	7,865,355	566,381	7.20%	566,381	0	0	0	0	0	0	0	0	0	0	0
1142	អាករពិសេស	5,459,550	316,037	5.79%	316,037	0	0	0	0	0	0	0	0	0	0	0
115	**ពន្ធលើពាណិជ្ជកម្មអន្តរជាតិ**	2,517,222	173,882	6.91%	173,882	0	0	0	0	0	0	0	0	0	0	0
1151	អាករ និងបន្ទុកនាំចូលផ្សេងៗ	2,469,895	172,713	6.99%	172,713	0	0	0	0	0	0	0	0	0	0	0
1152	ពន្ធនាំចេញ	47,327	1,169	2.47%	1,169	0	0	0	0	0	0	0	0	0	0	0
13	**អំណោយ**	**912,569**	**58,215**	**6.38%**	**58,215**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**
131	**អំណោយពីរដ្ឋាភិបាលបរទេស**	333,559	17,465	5.24%	17,465	0	0	0	0	0	0	0	0	0	0	0
1312	មូលធន	333,559	17,465	5.24%	17,465	0	0	0	0	0	0	0	0	0	0	0
132	**អំណោយពីអង្គការអន្តរជាតិ**	579,010	40,751	7.04%	40,751	0	0	0	0	0	0	0	0	0	0	0
1322	មូលធន	489,010	40,751	8.33%	40,751	0	0	0	0	0	0	0	0	0	0	0
14	**ចំណូលផ្សេងៗ**	**2,234,306**	**118,308**	**5.30%**	**118,308**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**
141	**ចំណូលពីទ្រព្យសម្បត្តិ**	409,738	22,932	5.60%	22,932	0	0	0	0	0	0	0	0	0	0	0
1411	ចំណូលការប្រាក់	211,638	…	…	0	0	0	0	0	0	0	0	0	0	0	0
14112	ចំណូលការប្រាក់ក្នុងប្រទេស	211,638	…	…	0	0	0	0	0	0	0	0	0	0	0	0
1412	ចំណូលភាគលាភ	7,849	15	0.19%	15	0	0	0	0	0	0	0	0	0	0	0
1413	ចំណូលផលទុននៃសេវាផ្គត់ផ្គង់ (អគ្គិសនី, ទឹក...)	0	7	…	7	0	0	0	0	0	0	0	0	0	0	0
1415	ចំណូលពីការជួល	190,250	22,910	12.04%	22,910	0	0	0	0	0	0	0	0	0	0	0
142	**ចំណូលពីការលក់ទំនិញ និងសេវាកម្ម**	1,569,236	76,064	4.85%	76,064	0	0	0	0	0	0	0	0	0	0	0
1421	ចំណូលពីការលក់ក្នុងទីផ្សារ	802,405	27,304	3.40%	27,304	0	0	0	0	0	0	0	0	0	0	0
1422	ចំណូលសេវារដ្ឋបាល	672,416	39,431	5.86%	39,431	0	0	0	0	0	0	0	0	0	0	0
1423	ចំណូលពីការលក់ ឬសកម្មភាពផ្សេងៗ (ទេសចរណ៍, វប្បធម៌...)	94,415	9,329	9.88%	9,329	0	0	0	0	0	0	0	0	0	0	0

(១). មិនរួមបញ្ចូលគ្រឹះស្ថានសាធារណៈរដ្ឋបាល

២.តារាងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (រដ្ឋបាលថ្នាក់ជាតិ) (១)

២.២.តារាងស្ថិតិប្រតិបត្តិការចំណូល

ឯកតា÷ លានរៀល

		ច្បាប់ឆ្នាំ ២០២៣	អនុវត្តន៍ ឆ្នាំ២០២៣	អនុ/ច្បា ២០២៣	មករា ២៣	កុម្ភៈ ២៣	មីនា ២៣	មេសា ២៣	ឧសភា ២៣	មិថុនា ២៣	កក្កដា ២៣	សីហា ២៣	កញ្ញា ២៣	តុលា ២៣	វិច្ឆិកា ២៣	ធ្នូ ២៣
	វិធីសាស្ត្រគណនយ្យ	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash
143	**ចំណូលបានពីការពិន័យ**	253,027	19,096	7.55%	19,096	0	0	0	0	0	0	0	0	0	0	0
144	**ការផ្ទេរផ្សេងៗដែលមិនបានញែក**	2,305	215	9.34%	215	0	0	0	0	0	0	0	0	0	0	0
1441	ចរន្ត	2,305	215	9.34%	215	0	0	0	0	0	0	0	0	0	0	0
14412	ផ្សេងៗ	2,305	215	9.34%	215	0	0	0	0	0	0	0	0	0	0	0

(១).មិនរួមបញ្ចូលគ្រឹះស្ថានសាធារណៈរដ្ឋបាល

២.តារាងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (រដ្ឋបាលថ្នាក់ជាតិ) (១)

២.៣.តារាងស្ថិតិប្រតិបត្តិការចំណាយ

ឯកតា÷ លានរៀល

		ច្បាប់ឆ្នាំ ២០២៣	អនុវត្តន៍ ឆ្នាំ២០២៣	អនុ/ច្បា ២០២៣	មករា ២៣	កុម្ភៈ ២៣	មីនា ២៣	មេសា ២៣	ឧសភា ២៣	មិថុនា ២៣	កក្កដា ២៣	សីហា ២៣	កញ្ញា ២៣	តុលា ២៣	វិច្ឆិកា ២៣	ធ្នូ ២៣
	វិធីសាស្ត្រគណនេយ្យ	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash
2	**ចំណាយ**	**18,748,112**	**714,316**	**3.81%**	**714,316**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**
21	**បន្ទុកបុគ្គលិក**	**8,616,086**	**604,942**	**7.02%**	**604,942**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**
211	**ប្រាក់ខែ**	8,616,086	604,942	7.02%	604,942	0	0	0	0	0	0	0	0	0	0	0
22	**ទំនិញ និងសេវាកម្ម**	**3,299,407**	**29,134**	**0.88%**	**29,134**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**
24	**ការប្រាក់**	**769,491**	**61,328**	**7.97%**	**61,328**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**
241	**បំណុលក្រៅប្រទេស**	769,491	61,328	7.97%	61,328	0	0	0	0	0	0	0	0	0	0	0
25	**ការឧបត្ថម្ភធន**	**9,000**	**…**	**…**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**
251	**សហគ្រាសសាធារណៈ**	9,000	…	…	0	0	0	0	0	0	0	0	0	0	0	0
26	**អំណោយ**	**2,975,375**	**1,209**	**0.04%**	**1,209**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**
262	**អង្គការអន្តរជាតិ**	155,529	…	…	0	0	0	0	0	0	0	0	0	0	0	0
2621	ចរន្ត	155,529	…	…	0	0	0	0	0	0	0	0	0	0	0	0
263	**រដ្ឋាភិបាលដទៃទៀត (រដ្ឋបាលថ្នាក់ក្រោមជាតិ,...)**	2,819,845	1,209	0.04%	1,209	0	0	0	0	0	0	0	0	0	0	0
2631	ចរន្ត	2,819,845	1,209	0.04%	1,209	0	0	0	0	0	0	0	0	0	0	0
27	**ឧបត្ថម្ភសង្គមកិច្ច**	**2,091,777**	**10,655**	**0.51%**	**10,655**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**
271	**អត្ថប្រយោជន៍សន្តិសុខសង្គម**	1,330,745	…	…	0	0	0	0	0	0	0	0	0	0	0	0
272	**អត្ថប្រយោជន៍ជំនួយសង្គម**	500,703	148	0.03%	148	0	0	0	0	0	0	0	0	0	0	0
273	**អត្ថប្រយោជន៍សង្គមសម្រាប់មន្ត្រីរាជការ**	260,329	10,506	4.04%	10,506	0	0	0	0	0	0	0	0	0	0	0
28	**ចំណាយផ្សេងៗ**	**986,976**	**7,048**	**0.71%**	**7,048**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**
282	**ការផ្ទេរផ្សេងៗដែលមិនបានបែងចែក**	984,564	7,048	0.72%	7,048	0	0	0	0	0	0	0	0	0	0	0
2821	ចរន្ត	984,564	7,048	0.72%	7,048	0	0	0	0	0	0	0	0	0	0	0
283	**បុព្វលាភធានារ៉ាប់រង, និងផ្សេងៗ**	2,412	…	…	0	0	0	0	0	0	0	0	0	0	0	0
2831	បុព្វលាភធានារ៉ាប់រងចរន្ត	2,412	…	…	0	0	0	0	0	0	0	0	0	0	0	0
28311	បុព្វលាភធានារ៉ាប់រង	2,412	…	…	0	0	0	0	0	0	0	0	0	0	0	0

(១). មិនរួមបញ្ចូលគ្រឹះស្ថានសាធារណៈរដ្ឋបាល

២.តារាងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (រដ្ឋបាលថ្នាក់ជាតិ) (១)

២.៤.តារាងស្ថិតិប្រតិបត្តិការទ្រព្យសកម្ម និងបំណុល

ឯកតា÷ លានរៀល

		ច្បាប់ឆ្នាំ ២០២៣	អនុវត្តន៍ ឆ្នាំ២០២៣	អនុ/ច្បា ២០២៣	មករា ២៣	កុម្ភៈ ២៣	មីនា ២៣	មេសា ២៣	ឧសភា ២៣	មិថុនា ២៣	កក្កដា ២៣	សីហា ២៣	កញ្ញា ២៣	តុលា ២៣	វិច្ឆិកា ២៣	ធ្នូ ២៣
	វិធីសាស្ត្រគណនេយ្យ	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash
3	**បម្រែបម្រួលតម្លៃសុទ្ធនៃទ្រព្យកម្ម**	**7,498,879**	**1,184,604**	**15.80%**	**1,184,604**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**
31	**ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ**	**14,141,846**	**361,173**	**2.55%**	**361,173**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**
311	**អចលនទ្រព្យ**	14,141,846	361,173	2.55%	361,173	0	0	0	0	0	0	0	0	0	0	0
311A	***ការទិញ÷ អចលនទ្រព្យ***	14,141,852	361,173	2.55%	361,173	0	0	0	0	0	0	0	0	0	0	0
311B	***ការលក់÷ អចលនទ្រព្យ***	6	0	0.15%	0	0	0	0	0	0	0	0	0	0	0	0
3111	អាគារ និងសំណង់ផ្សេងៗ	13,734,386	296,813	2.16%	296,813	0	0	0	0	0	0	0	0	0	0	0
3111A	*ការទិញ÷ អាគារ និងសំណង់ផ្សេងៗ*	13,734,386	296,813	2.16%	296,813	0	0	0	0	0	0	0	0	0	0	0
3111B	*ការលក់÷ អាគារ និងសំណង់ផ្សេងៗ*	0	0	…	0	0	0	0	0	0	0	0	0	0	0	0
3112	ម៉ាស៊ីន និងសម្ភារបរិក្ខារ	407,466	64,360	15.80%	64,360	0	0	0	0	0	0	0	0	0	0	0
3112A	*ការទិញ÷ ម៉ាស៊ីន និងសម្ភារបរិក្ខារ*	407,466	64,360	15.80%	64,360	0	0	0	0	0	0	0	0	0	0	0
3113	អចលនទ្រព្យផ្សេងៗ	-6	…	…	0	0	0	0	0	0	0	0	0	0	0	0
3113B	*ការលក់÷ អចលនទ្រព្យផ្សេងៗ*	6	…	…	0	0	0	0	0	0	0	0	0	0	0	0
32	**ទ្រព្យសកម្មហិរញ្ញវត្ថុសុទ្ធ**	**-1,056,500**	**906,402**	**…**	**906,402**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**
3202	រូបិយប័ណ្ណ និងប្រាក់បញ្ញើ	-724,688	906,402	…	906,402	0	0	0	0	0	0	0	0	0	0	0
3204	កម្ចី	-331,812	…	…	0	0	0	0	0	0	0	0	0	0	0	0
321	**ក្នុងស្រុក**	-1,056,500	906,402	…	906,402	0	0	0	0	0	0	0	0	0	0	0
3212	រូបិយប័ណ្ណ និងប្រាក់បញ្ញើ	-724,688	906,402	…	906,402	0	0	0	0	0	0	0	0	0	0	0
3214	កម្ចី	-331,812	…	…	0	0	0	0	0	0	0	0	0	0	0	0
33	**បំណុលសុទ្ធ**	**5,586,468**	**82,971**	**1.49%**	**82,971**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**	**0**
3303	មូលបត្របំណុល	0	…	…	0	0	0	0	0	0	0	0	0	0	0	0
3304	កម្ចី	4,773,468	82,971	1.74%	82,971	0	0	0	0	0	0	0	0	0	0	0
331	**ក្នុងស្រុក**	813,000	…	…	0	0	0	0	0	0	0	0	0	0	0	0
3313	មូលបត្របំណុល	0	…	…	0	0	0	0	0	0	0	0	0	0	0	0
332	**ក្រៅស្រុក**	4,773,468	82,971	1.74%	82,971	0	0	0	0	0	0	0	0	0	0	0
3324	កម្ចី	4,773,468	82,971	1.74%	82,971	0	0	0	0	0	0	0	0	0	0	0

(១). មិនរួមបញ្ចូលគ្រឹះស្ថានសាធារណៈរដ្ឋបាល

២.តារាងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (រដ្ឋបាលថ្នាក់ជាតិ) (១)

២.៥.ក្រាហ្វិក









(១).មិនរួមបញ្ចូលគ្រឹះស្ថានសាធារណៈរដ្ឋបាល

២.តារាងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (រដ្ឋបាលថ្នាក់ជាតិ) (១)

២.៥. ក្រាហ្វិក









(១). មិនរួមបញ្ចូលគ្រឹះស្ថានសាធារណៈរដ្ឋបាល

៣.តារាងស្ថិតិប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល (សរុបថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) (១)

ឯកតា÷ លានរៀល

		អនុវត្តន៍ ឆ្នាំ២០១៥	អនុវត្តន៍ ឆ្នាំ២០១៦	អនុវត្តន៍ ឆ្នាំ២០១៧	អនុវត្តន៍ ឆ្នាំ២០១៨	អនុវត្តន៍ ឆ្នាំ២០១៩	អនុវត្តន៍ ឆ្នាំ២០២០	អនុវត្តន៍ ឆ្នាំ២០២១	អនុវត្តន៍ ឆ្នាំ២០២២ (២)	ច្បាប់ឆ្នាំ ២០២៣
	វិធីសាស្ត្រគណនេយ្យ	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash
1	**ចំណូល**	**14,409,681**	**16,913,325**	**19,386,752**	**23,599,112**	**29,461,178**	**25,334,068**	**23,041,022**	**27,203,012**	**28,714,617**
11	ពន្ធ	11,468,515	12,800,088	15,192,684	18,560,887	23,821,776	20,881,713	19,803,575	23,956,256	25,272,466
13	អំណោយ	1,427,542	2,010,468	1,706,636	2,132,905	2,200,916	2,043,869	1,101,597	884,351	912,569
14	ចំណូលផ្សេងៗ	1,513,624	2,102,769	2,487,431	2,905,319	3,438,486	2,408,487	2,135,851	2,362,405	2,529,582
2	**ចំណាយ**	**9,183,371**	**10,983,010**	**13,335,239**	**15,276,897**	**18,040,096**	**19,636,503**	**21,289,396**	**18,651,667**	**20,657,460**
21	បន្ទុកបុគ្គលិក	4,149,138	5,124,588	6,297,240	7,412,914	8,354,522	8,991,932	8,860,375	8,880,403	10,552,082
22	ទំនិញ និងសេវាកម្ម	2,841,265	3,120,399	3,650,346	4,092,509	4,984,054	4,197,578	6,139,325	4,034,254	5,282,725
24	ការប្រាក់	222,839	291,395	288,323	338,018	366,559	380,871	404,660	432,636	769,491
25	ឧបត្ថម្ភធន	20,700	82,080	225,055	10,485	616,400	371,001	45,184	…	…
26	អំណោយ	241,011	281,985	478,590	542,874	411,577	673,339	474,216	562,069	519,600
27	ឧបត្ថម្ភសង្គមកិច្ច	1,122,172	1,195,515	1,376,075	1,540,132	1,689,863	3,484,962	4,303,707	3,672,586	2,167,894
28	ចំណាយផ្សេងៗ	586,247	887,048	1,019,610	1,339,967	1,617,122	1,536,820	1,061,929	1,027,854	1,356,668
GOB	***តុល្យភាពប្រតិបត្តិការដុល***	**5,226,310**	**5,930,314**	**6,051,513**	**8,322,215**	**11,421,082**	**5,697,565**	**1,751,626**	**8,551,345**	**8,057,157**
NOB	***តុល្យភាពប្រតិបត្តិការសុទ្ធ***	**5,226,310**	**5,930,314**	**6,051,513**	**8,322,215**	**11,421,082**	**5,697,565**	**1,751,626**	**8,551,345**	**8,057,157**
31	**ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ**	5,700,652	6,173,782	6,747,191	7,663,907	8,161,278	9,300,353	9,403,441	6,505,911	14,705,779
311	ទ្រព្យអចលតៃ	5,688,350	6,149,369	6,742,610	7,526,577	8,096,314	9,255,187	9,279,562	6,461,382	14,679,009
314	ទ្រព្យសកម្មគ្មានផលិតភាព	12,301	24,412	4,581	137,330	64,964	45,167	123,879	44,529	26,770
2M	**ចំណាយសរុប**	14,884,022	17,156,792	20,082,430	22,940,804	26,201,374	28,936,856	30,692,837	25,157,578	35,363,239
NLB	***សមតុល្យនៃការផ្តល់កម្ចី ឬទទួលកម្ចី***	**(474,341)**	**(243,467)**	**(695,678)**	**658,308**	**3,259,804**	**(3,602,788)**	**(7,651,815)**	**2,045,434**	**(6,648,622)**
32	**ទ្រព្យហិរញ្ញវត្ថុសុទ្ធ**	1,883,927	1,626,246	2,939,691	3,073,469	6,205,762	313,863	(4,035,985)	6,761,677	(921,619)
321	ក្នុងប្រទេស	1,883,927	1,626,246	2,939,691	3,073,469	6,205,762	313,863	(4,035,985)	6,761,677	(921,619)
33	**បំណុលសុទ្ធ**	2,358,197	1,869,715	1,889,811	1,990,432	2,948,819	3,916,651	3,617,184	4,716,243	5,586,468
331	ក្នុងប្រទេស	220,291	115,194	(466,421)	113,596	465,002	46,464	…	1,065,156	813,000
332	ក្រៅប្រទេស	2,137,905	1,754,521	2,356,231	1,876,836	2,483,817	3,870,187	3,808,715	3,651,087	4,773,468

(១) មិនរួមបញ្ចូលទិន្នន័យគ្រឹះស្ថានសាធារណៈរដ្ឋបាល និងទិន្នន័យបេឡាជាតិរបបសន្តិសុខសង្គម

(២) តួលេខបណ្តោះអាសន្ន

៤.តារាងស្ថិតិប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល (ថ្នាក់ជាតិ)

ឯកតា÷ លានរៀល

		អនុវត្តន៍ ឆ្នាំ២០១៥	អនុវត្តន៍ ឆ្នាំ២០១៦	អនុវត្តន៍ ឆ្នាំ២០១៧	អនុវត្តន៍ ឆ្នាំ២០១៨	អនុវត្តន៍ ឆ្នាំ២០១៩	អនុវត្តន៍ ឆ្នាំ២០២០	អនុវត្តន៍ ឆ្នាំ២០២១	អនុវត្តន៍ ឆ្នាំ២០២២ (១)	ច្បាប់ឆ្នាំ ២០២៣
	វិធីសាស្ត្រគណនេយ្យ	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash
1	**ចំណូល**	**13,589,225**	**16,102,389**	**18,332,979**	**21,956,885**	**27,269,838**	**23,153,071**	**21,770,209**	**25,044,368**	**26,246,991**
11	ពន្ធ	10,707,143	12,044,830	14,183,089	16,974,374	21,708,033	18,938,923	18,084,219	22,088,509	23,100,116
13	អំណោយ	1,422,766	2,008,955	1,704,556	2,128,129	2,194,160	2,031,391	1,717,043	821,431	912,569
14	ចំណូលផ្សេងៗ	1,459,316	2,048,604	2,445,334	2,854,382	3,367,645	2,182,757	1,968,946	2,134,428	2,234,306
2	**ចំណាយ**	**8,838,263**	**10,538,002**	**12,798,116**	**14,453,941**	**17,356,854**	**18,436,418**	**20,386,125**	**17,921,635**	**18,748,112**
21	បន្ទុកបុគ្គលិក	3,924,062	4,815,589	5,953,521	6,994,459	7,853,824	8,357,188	7,715,076	7,581,380	8,616,086
22	ទំនិញ និងសេវាកម្ម	2,156,292	2,423,808	2,807,262	3,057,066	3,184,358	2,902,485	2,777,280	2,396,101	3,299,407
24	ការប្រាក់	222,839	291,395	288,323	338,018	366,559	380,871	403,261	432,636	769,491
25	ឧបត្ថម្ភធន	20,700	82,080	225,055	10,485	611,600	327,400	3,155	…	9,000
26	អំណោយ	870,490	915,781	1,220,952	1,314,732	2,351,599	1,620,992	2,375,009	3,175,510	2,975,375
27	ឧបត្ថម្ភសង្គមកិច្ច	1,112,463	1,184,011	1,359,717	1,523,618	1,674,326	3,469,400	3,362,485	3,604,444	2,091,777
28	ចំណាយផ្សេងៗ	531,416	825,339	943,287	1,215,563	1,314,588	1,378,081	3,749,859	731,564	986,976
GOB	***តុល្យភាពប្រតិបត្តិការដុល***	**4,750,962**	**5,564,387**	**5,534,863**	**7,502,944**	**9,912,984**	**4,716,653**	**1,384,084**	**7,122,733**	**7,498,879**
NOB	***តុល្យភាពប្រតិបត្តិការសុទ្ធ***	**4,750,962**	**5,564,387**	**5,534,863**	**7,502,944**	**9,912,984**	**4,716,653**	**1,384,084**	**7,122,733**	**7,498,879**
31	**ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ**	5,387,432	5,879,159	6,442,470	7,129,990	7,516,027	8,651,989	9,172,556	5,799,520	14,141,846
311	ទ្រព្យអចលត៏	5,376,656	5,872,697	6,437,929	6,993,155	7,465,277	8,611,007	9,056,933	5,759,973	14,141,846
314	ទ្រព្យសកម្មគ្មានផលិតភាព	10,776	6,462	4,542	136,836	50,750	40,983	115,623	39,547	-
2M	**ចំណាយសរុប**	14,225,695	16,417,161	19,240,587	21,583,931	24,872,881	27,088,407	29,558,681	23,721,156	32,889,958
NLB	***សមតុល្យនៃការផ្តល់កម្ចី ឬទទួលកម្ចី***	**(636,470)**	**(314,772)**	**(907,608)**	**372,954**	**2,396,958**	**(3,935,336)**	**(7,788,472)**	**1,323,213**	**(6,642,968)**
32	**ទ្រព្យហិរញ្ញវត្ថុសុទ្ធ**	1,612,179	1,574,127	2,606,213	2,225,434	4,877,914	(65,149)	(4,216,573)	5,040,399	(1,056,500)
321	ក្នុងប្រទេស	1,612,179	1,574,127	2,606,213	2,225,434	4,877,914	(65,149)	(4,216,573)	5,040,399	(1,056,500)
33	**បំណុលសុទ្ធ**	2,248,578	1,888,899	1,768,263	1,876,836	2,483,817	3,870,187	3,571,899	3,717,187	5,586,468
331	ក្នុងប្រទេស	110,672	134,378	(587,968)	…	…	…	…	66,100	813,000
332	ក្រៅប្រទេស	2,137,905	1,754,521	2,356,231	1,876,836	2,483,817	3,870,187	3,571,899	3,651,087	4,773,468

(១) តួលេខបណ្តោះអាសន្ន

៥.តារាងស្ថិតិប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល (រដ្ឋបាលថ្នាក់ក្រោមជាតិ) (១)

ឯកតា÷ លានរៀល

		អនុវត្តន៍ ឆ្នាំ២០១៥	អនុវត្តន៍ ឆ្នាំ២០១៦	អនុវត្តន៍ ឆ្នាំ២០១៧	អនុវត្តន៍ ឆ្នាំ២០១៨	អនុវត្តន៍ ឆ្នាំ២០១៩	អនុវត្តន៍ ឆ្នាំ២០២០	អនុវត្តន៍ ឆ្នាំ២០២១	អនុវត្តន៍ ឆ្នាំ២០២២ (២)	ច្បាប់ឆ្នាំ ២០២៣
	វិធីសាស្ត្រគណនេយ្យ	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash	Non Cash
1	ចំណូល	**1,449,977**	**1,444,774**	**1,796,173**	**2,863,180**	**3,964,681**	**3,129,128**	**4,364,641**	**4,772,094**	**4,923,440**
11	ពន្ធ	761,372	755,258	1,009,595	1,586,513	2,113,743	1,942,790	1,785,773	1,867,747	2,172,350
13	អំណោយ	634,297	635,351	744,480	1,225,729	1,780,097	960,609	2,310,308	2,676,370	2,455,814
14	ចំណូលផ្សេងៗ	54,308	54,165	42,098	50,938	70,841	225,729	268,560	227,977	295,276
2	ចំណាយ	**974,629**	**1,078,847**	**1,279,522**	**1,594,825**	**2,456,489**	**2,148,216**	**3,307,677**	**3,343,482**	**4,365,162**
21	បន្ទុកបុគ្គលិក	225,075	309,000	343,718	418,455	500,698	634,744	1,299,464	1,299,023	1,935,996
22	ទំនិញ និងសេវាកម្ម	684,973	696,591	843,085	1,035,442	1,799,696	1,295,093	1,662,134	1,638,154	1,983,318
25	ឧបត្ថម្ភធន	…	…	…	…	4,800	43,601	42,029	41,864	-
26	អំណោយ	42	43	37	10	8	478	2,535	9	40
27	ឧបត្ថម្ភសង្គមកិច្ច	9,709	11,504	16,358	16,514	15,537	15,562	69,086	68,142	76,117
28	ចំណាយផ្សេងៗ	54,830	61,709	76,323	124,404	135,751	158,738	232,429	296,290	369,692
GOB	តុល្យភាពប្រតិបត្តិការដុល	**475,349**	**365,927**	**516,651**	**1,268,356**	**1,508,192**	**980,912**	**1,056,964**	**1,428,612**	**558,278**
NOB	តុល្យភាពប្រតិបត្តិការសុទ្ធ	**475,349**	**365,927**	**516,651**	**1,268,356**	**1,508,192**	**980,912**	**1,056,964**	**1,428,612**	**558,278**
31	ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ	313,219	294,622	304,721	533,917	645,251	648,364	658,418	706,391	563,933
311	ទ្រព្យអចលត៌	311,694	276,672	304,681	533,422	631,037	644,180	650,162	701,409	537,163
314	ទ្រព្យសកម្មគ្មានផលិតភាព	1,525	17,950	39	494	14,214	4,184	8,256	4,982	26,770
2M	ចំណាយសរុប	1,287,848	1,373,470	1,584,243	2,128,741	3,101,741	2,796,580	3,966,095	4,049,873	4,929,095
NLB	សមតុល្យនៃការផ្តល់កម្ចី ឬទទួលកម្ចី	**162,129**	**71,305**	**211,930**	**734,439**	**862,941**	**332,548**	**398,546**	**722,222**	**(5,655)**
32	ទ្រព្យហិរញ្ញវត្ថុសុទ្ធ	271,748	52,119	333,478	848,035	1,327,848	379,012	207,015	1,721,277	134,881
321	ក្នុងប្រទេស	271,748	52,119	333,478	848,035	1,327,848	379,012	207,015	1,721,277	134,881
33	បំណុលសុទ្ធ	109,619	(19,184)	121,548	113,596	464,907	46,464	(191,530)	999,056	-
331	ក្នុងប្រទេស	109,619	(19,184)	121,548	113,596	464,907	46,464	(191,530)	999,056	-

(១) ស្ថិតិសមាសរវាងរដ្ឋបាលថ្នាក់ក្រោមជាតិទាំង ៣ កម្រិត

(២) តួលេខបណ្តោះអាសន្ន

៦.ភាពខុសគ្នារវាងស្ថិតិ GFS និងស្ថិតិ TOFE (១)

តារាងស្ថិតិស្តីពីភាពខុសគ្នារវាងស្ថិតិ GFS និងស្ថិតិ TOFE	ច្បាប់ឆ្នាំ ២០២៣	អនុវត្តន៍ ២០២៣	អនុ/ច្ប ២០២៣	មករា ២៣	កុម្ភៈ ២៣	មីនា ២៣	មេសា ២៣	ឧសភា ២៣	មិថុនា ២៣	កក្កដា ២៣	សីហា ២៣	កញ្ញា ២៣	តុលា ២៣	វិច្ឆិកា ២៣	ធ្នូ ២៣
ស្ថិតិ TOFE÷ ចំណូលក្នុងប្រទេស	**25,896,240**	**1,853,478**	**7.16%**	**1,853,478**	-	-	-	-	-	-	-	-	-	-	-
បូក÷	*822,569*	*58,215*		*58,215*	-	-	-	-	-	-	-	-	-	-	-
អំណោយ-ទ្រទ្រង់ថវិកា	*123,983*	-		-	-	-	-	-	-	-	-	-	-	-	-
អំណោយ	*698,586*	*58,215*		*58,215*	-	-	-	-	-	-	-	-	-	-	-
ដក÷	*471,818*	*12,773*		*12,773*	-	-	-	-	-	-	-	-	-	-	-
ការបង្វិលសងវិញនូវពន្ធនិងអាករផ្សេងៗ	*140,000*	*12,433*		*12,433*	-	-	-	-	-	-	-	-	-	-	-
ផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ	-	*0*		*0*	-	-	-	-	-	-	-	-	-	-	-
ផលហិរញ្ញវត្ថុផ្សេងទៀត	-	*340*		*340*	-	-	-	-	-	-	-	-	-	-	-
ចំណូលពីការលក់អគារជម្រះបញ្ជីសារពើភណ្ឌ	-	-		-	-	-	-	-	-	-	-	-	-	-	-
ចំណូលពីការលក់រថយន្ត ឧបករណ៍ និងសម្ភារបរិក្ខារជាអចលវត្ថុ	*6*	-		-	-	-	-	-	-	-	-	-	-	-	-
ការឲ្យខ្ចី (ការសងវិញនូវមូលធន)	*331,812*	-		-	-	-	-	-	-	-	-	-	-	-	-
ស្ថិតិ GFS÷ ចំណូល	**26,246,991**	**1,898,920**	**7.23%**	**1,898,920**	-	-	-	-	-	-	-	-	-	-	-
ស្ថិតិ TOFE÷ ចំណាយសរុប	**34,743,811**	**1,035,155**	**2.98%**	**1,035,155**	-	-	-	-	-	-	-	-	-	-	-
បូក÷	-	*(340)*		*(340)*	-	-	-	-	-	-	-	-	-	-	-
ផលហិរញ្ញវត្ថុផ្សេងទៀត	-	*(340)*		*(340)*	-	-	-	-	-	-	-	-	-	-	-
ផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ	-	*(0)*		*(0)*	-	-	-	-	-	-	-	-	-	-	-
ចំណូលពីការលក់អគារជម្រះបញ្ជីសារពើភណ្ឌ	-	-		-	-	-	-	-	-	-	-	-	-	-	-
ចំណូលពីការលក់រថយន្ត ឧបករណ៍ និងសម្ភារបរិក្ខារជាអចលវត្ថុ	*(6)*	-		-	-	-	-	-	-	-	-	-	-	-	-
ដក÷	*1,853,847*	*12,433*		*12,433*	-	-	-	-	-	-	-	-	-	-	-
ការបង្វិលសងវិញនូវពន្ធនិងអាករផ្សេងៗ	*140,000*	*12,433*		*12,433*	-	-	-	-	-	-	-	-	-	-	-
ការវិនិយោគ	-	-		-	-	-	-	-	-	-	-	-	-	-	-
ចំណាយមិនបានគ្រោងទុក	*1,713,847*	-		-	-	-	-	-	-	-	-	-	-	-	-
ការឲ្យខ្ចី (ការសងវិញនូវមូលធន)	-	-		-	-	-	-	-	-	-	-	-	-	-	-
ស្ថិតិ GFS÷ ចំណាយសរុប	**32,889,958**	**1,075,489**	**3.27%**	**1,075,489**	-	-	-	-	-	-	-	-	-	-	-
ស្ថិតិ TOFE÷ តុល្យភាពសរុប ឱនភាព/អតិរេក (I-II)	**(8,847,571)**	**818,322**	**…**	**818,322**	-	-	-	-	-	-	-	-	-	-	-
បូក÷	*2,536,416*	*58,215*		*58,215*	-	-	-	-	-	-	-	-	-	-	-
ការឲ្យខ្ចី (ការសងវិញនូវមូលធន)	-	-		-	-	-	-	-	-	-	-	-	-	-	-
អំណោយ-ទ្រទ្រង់ថវិកា	*123,983*	-		-	-	-	-	-	-	-	-	-	-	-	-
អំណោយ	*698,586*	*58,215*		*58,215*	-	-	-	-	-	-	-	-	-	-	-
ចំណាយមិនបានគ្រោងទុក	*1,713,847*	-		-	-	-	-	-	-	-	-	-	-	-	-
ដក÷	*331,812*	-		-	-	-	-	-	-	-	-	-	-	-	-
២.ចំណាយមូលធន	*331,812*	-		-	-	-	-	-	-	-	-	-	-	-	-
ការវិនិយោគ	-	-		-	-	-	-	-	-	-	-	-	-	-	-
ស្ថិតិ GFS÷ សមតុល្យនៃការអោយខ្ចី/ប្រាក់កម្ចី	**(6,642,968)**	**823,431**	**…**	**823,431**	-	-	-	-	-	-	-	-	-	-	-
ស្ថិតិ TOFE÷ ហិរញ្ញប្បទានពីក្រៅប្រទេស	**6,409,036**	**107,554**	**1.68%**	**107,554**	-	-	-	-	-	-	-	-	-	-	-
ដក÷	*822,569*	*58,215*		*58,215*	-	-	-	-	-	-	-	-	-	-	-
អំណោយ-ទ្រទ្រង់ថវិកា	*123,983*	-		-	-	-	-	-	-	-	-	-	-	-	-
អំណោយ	*698,586*	*58,215*		*58,215*	-	-	-	-	-	-	-	-	-	-	-
ស្ថិតិ GFS÷ បំណុលសុទ្ធ	**5,586,468**	**82,971**	**1.49%**	**82,971**	-	-	-	-	-	-	-	-	-	-	-
ស្ថិតិ TOFE÷ ហិរញ្ញប្បទានក្នុងស្រុក	**-**	**33,129**	**0.00%**	**33,129**	-	-	-	-	-	-	-	-	-	-	-
បូក÷	*(1,446,048)*	*873,273*		*873,273*	-	-	-	-	-	-	-	-	-	-	-
ការវិនិយោគក្នុងញាតិសម្ព័ន្ធនិងការវិនិយោគទុនរួមគ្នា	-	-		-	-	-	-	-	-	-	-	-	-	-	-
ការឲ្យខ្ចី (ការសងវិញនូវមូលធន)	*(331,812)*	-	-	-	-	-	-	-	-	-	-	-	-	-	-
ប្រតិបត្តិការកំពុងដំណើរការ	-	*939,531*		*939,531*	-	-	-	-	-	-	-	-	-	-	-
ប្រាក់បញ្ញើរាជរដ្ឋាភិបាល	*(1,114,236)*	*(66,259)*		*(66,259)*	-	-	-	-	-	-	-	-	-	-	-
ស្ថិតិ GFS÷ ទ្រព្យហិរញ្ញវត្ថុសុទ្ធ	**(1,056,500)**	**906,402**	**-85.79%**	**906,402**	-	-	-	-	-	-	-	-	-	-	-

(១).សេចក្តីពន្យល់ពីភាពខុសគ្នារវាងស្ថិតិ GFS និងស្ថិតិ TOFE មាននៅក្នុងចំណុចទី៣ នៃសេចក្តីសង្ខេបអំពី "ក្របខ័ណ្ឌប្រព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល"

៧.សេចក្តីសង្ខេបស្តីអំពី "ក្របខ័ណ្ឌប្រព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល" អនុលោមទៅតាម Government Finance Statistics Manual (GFSM2014)

១.វិសាលភាពស្ថាប័នក្នុងប្រព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលកម្ពុជា

១.១. ក្នុងប្រព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលកម្ពុជា វិស័យរដ្ឋាភិបាលទូទៅ (General Government) សំដៅដល់គ្រប់អង្គភាព ស្ថាប័នសាធារណៈប្រហាក់ប្រហែលទាំងអស់ ស្ថាប័នអង្គនីតិបញ្ញត្តិ ស្ថាប័នអង្គនីតិប្រតិបត្តិ និងស្ថាប័នតុលាការ -ល-, ដែលមានមុខងារស្នូលក្នុងការផ្តល់សេវាសាធារណៈ ដោយមិនផ្អែកលើគោលការណ៍ ឬតម្លៃទីផ្សារ (Non-Market Producer) ឡើយ។ ជាទូទៅ វិស័យនេះ មានវិសាលភាពគ្របដណ្តប់ដល់រដ្ឋបាលច្រើនកម្រិត ដូចជារដ្ឋបាលថ្នាក់ជាតិ (Central Government), រដ្ឋបាលសហព័ន្ធ (State Government), រដ្ឋបាលថ្នាក់ក្រោមជាតិ (Local Government) និង/ឬ បេឡាជាតិសន្តិសុខសង្គម (NSSF)។ ជាក់ស្តែង ប្រទេសនីមួយៗ បានបែងចែកកម្រិតរដ្ឋបាលរបស់ខ្លួន ផ្អែកលើការរៀបចំមុខងាររដ្ឋបាល និងមុខងារនីតិកម្មរបស់រាជរដ្ឋាភិបាល ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជា មាន ២ កម្រិត គឺរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

១.២. យោងតាមព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៨ ស្តីពី "ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ" ចែងថា រដ្ឋបាលថ្នាក់ជាតិ (Central Government) សំដៅដល់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងមន្ទីរជំនាញក្រោមឱវាទ។ រដ្ឋបាលថ្នាក់ជាតិ បែងចែកជា ៣ អនុកម្រិត គឺរដ្ឋបាលថ្នាក់ជាតិមិនរួមបញ្ចូលគ្រឹះស្ថានសាធារណៈរដ្ឋបាល, គ្រឹះស្ថានសាធារណៈរដ្ឋបាល, និងបេឡាជាតិសន្តិសុខសង្គម។ ជាក់ស្តែង រដ្ឋបាលកម្រិតនេះ មានសិទ្ធិអំណាចក្នុងការរៀបចំ និងគ្រប់គ្រងគោលនយោបាយជាតិ, ទន្ទឹមនេះ មានអំណាចក្នុងការពង្រឹងសេដ្ឋកិច្ចរបស់ប្រទេស តាមរយៈការប្រមូលពន្ធ អាករផ្សេងៗ ពីគ្រប់និវាសជន និងអនិវាសជន ដែលមានសកម្មភាពសេដ្ឋកិច្ចក្នុងទឹកដីប្រទេសកម្ពុជា ជាដើម។ លើសពីនេះ រដ្ឋបាលថ្នាក់ជាតិ មានកាតព្វកិច្ចក្នុងការផ្តល់សេវា សម្រាប់ផលប្រយោជន៍របស់ប្រទេសទាំងមូល, រួមបញ្ចូលទាំងការចំណាយក្នុងរូបភាពជាការឧបត្ថម្ភ (អំណោយ) ដល់រដ្ឋបាលកម្រិតផ្សេងៗទៀត រួមមានរដ្ឋបាលថ្នាក់ក្រោមជាតិ ជាដើម។

១.៣. រដ្ឋបាលថ្នាក់ជាតិមិនរួមបញ្ចូលគ្រឹះស្ថានសាធារណៈរដ្ឋបាល (Budgetary Central Government) សំដៅដល់ក្រសួង ស្ថាប័ន មន្ទីរជំនាញប្រហាក់ប្រហែល ដែលបំពេញមុខងារនៃអំណាចទាំង ៣ រួមមាន អំណាចនីតិបញ្ញត្តិ អំណាចអង្គនីតិប្រតិបត្តិ និងអំណាចតុលាការ។ ជាក់ស្តែង ក្រសួង ស្ថាប័ន ដែលស្ថិតក្រោមអនុកម្រិតនេះ ពុំមានសិទ្ធិទទួលបានការកាន់កាប់ដោយផ្ទាល់លើទ្រព្យសកម្ម, ទ្រព្យអកម្ម (ខ្ចីបំណុល), ឬអនុវត្តប្រតិបត្តិការនានាឡើយ ពោលគឺរាល់ប្រតិបត្តិការចំណូល និងចំណាយ ត្រូវស្ថិតក្រោមការកំណត់ដោយច្បាប់ហិរញ្ញវត្ថុ និងការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

១.៤. គ្រឹះស្ថានសាធារណៈរដ្ឋបាល (Extra Budgetary Central Government) គឺជាអង្គភាពមានថវិកាស្វយ័ត និងត្រូវបានបង្កើតឡើងសំដៅទទួលបន្ទុកផ្តល់សេវាផ្នែកសាធារណៈមានលក្ខណៈរដ្ឋបាល ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ យោងតាមព្រះរាជក្រឹត្យលេខ នស/រកត/០៨០១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពី "លក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល" ចែងថា គ្រឹះស្ថានសាធារណៈរដ្ឋបាល គឺជានីតិបុគ្គលនៃនីតិសាធារណៈ ដែលទទួលបន្ទុកចម្បងនូវបេសកកម្មផ្នែកសេវាកម្មសាធារណៈ ជាអាទិ៍ សេវាមានលក្ខណៈរដ្ឋបាល សង្គមកិច្ច សុខាភិបាល វប្បធម៌ អប់រំ វិទ្យាសាស្ត្រ និងបច្ចេកទេស។ គិតត្រឹមចុងឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជាមានគ្រឹះស្ថានសាធារណៈរដ្ឋបាលសរុប ២៩ គ្រឹះស្ថាន។

១.៥. បេឡាជាតិសន្តិសុខសង្គម ត្រូវបានបង្កើតឡើងក្នុងគោលដៅបម្រើដល់ការរៀបចំ និងគ្រប់គ្រងប្រតិបត្តិការនានារបស់សេវាសន្តិសុខសង្គម។ ក្នុងបរិបទប្រទេសមួយចំនួន បេឡាជាតិសន្តិសុខសង្គម ស្ថិតក្រោមវិសាលភាពរបស់វិស័យរដ្ឋាភិបាលទូទៅ ប៉ុន្តែចំពោះបរិបទកម្ពុជាវិញ

អង្គភាពនេះគឺជាអនុកម្រិតមួយរបស់រដ្ឋបាលថ្នាក់ជាតិ និងស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

១.៦.រដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅដល់រាជធានី-ខេត្ត, ក្រុង-ស្រុក-ខណ្ឌ, និងឃុំ-សង្កាត់ ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ។ រដ្ឋបាលថ្នាក់ក្រោមជាតិ ជាស្ថាប័នឬអង្គភាពដែលមានសិទ្ធិអំណាចធ្វើវិមជ្ឈការ និងវិសហមជ្ឈការទៅលើអំណាចនីតិបញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ ដែលមានវិសាលភាពគ្របដណ្តប់លើតំបន់ភូមិសាស្ត្រនីមួយៗនៃផ្ទៃប្រទេសទាំងមូល។ ជាទូទៅ វិសាលភាពនៃសិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់នេះមានកម្រិតទាបជាងរដ្ឋបាលថ្នាក់ជាតិ និងការអនុវត្តមុខងារភាគច្រើន ពឹងផ្អែកលើការឧបត្ថម្ភ (អំណោយ) របស់រដ្ឋបាលថ្នាក់ជាតិ។

២.តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល

២.១. តារាងស្ថិតិប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាល សង្ខេបប្រតិបត្តិការសំខាន់ៗ របស់រាជរដ្ឋាភិបាល ដូចជា÷ ចំណូល, ចំណាយ, វិនិយោគសុទ្ធលើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ, វិនិយោគសុទ្ធលើទ្រព្យសកម្មហិរញ្ញវត្ថុ, និងការគ្រប់គ្រងបំណុល។ ប្រព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលនេះ បានកំណត់និយមន័យនៃប្រតិបត្តិការខាងលើដូចតទៅ÷ **ចំណូល** គឺជាប្រតិបត្តិការដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យសកម្ម (net worth) កើនឡើង។ ផ្ទុយទៅវិញ **ចំណាយ** គឺជាប្រតិបត្តិការដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យសកម្មថយចុះ។ ការវិនិយោគសុទ្ធលើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ គឺជាលទ្ធផលនៃអចលនទ្រព្យ (fixed assets) បូកសន្និធិសុទ្ធ, ទ្រព្យមានតម្លៃសុទ្ធ និងទ្រព្យគ្មានផលិតភាពសុទ្ធ (non-produce assets) ។

២.២. នៅក្នុងតារាងស្ថិតិប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាលមានតុល្យភាពចំនួន ០២ ដែលជាធាតុដ៏សំខាន់ក្នុងកិច្ចការវិភាគ។ តុល្យភាពទី១ គឺជាផលសងនៃចំណូល និងចំណាយ ដែលហៅថា **តុល្យភាពប្រតិបត្តិការសុទ្ធ** និងតុល្យភាពទី២ គឺជាផលសងនៃតុល្យភាពប្រតិបត្តិការសុទ្ធ និងការវិនិយោគលើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុសុទ្ធ ដែលហៅថា **សមតុល្យនៃការផ្តល់កម្ចី ឬការទទួលកម្ចី**។ តុល្យភាពទី២នេះ ក៏អាចបង្ហាញតាមរយៈផលសងនៃការវិនិយោគសុទ្ធលើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុល សុទ្ធ។

២.៣. តុល្យភាពប្រតិបត្តិការសុទ្ធ ទិន្នន័យតុល្យភាពនេះអាចយកទៅប្រៀបធៀបជាមួយគណនីជាតិតាមរយៈការបូកបញ្ចូលគ្នានៃការសន្សំ និងមូលនិធិផ្ទេរដែលត្រូវទទួល។ **តុល្យភាពប្រតិបត្តិការសុទ្ធ**នៅទីនេះមិនបានរាប់បញ្ចូលចំណេញ ឬខាតដែលកើតចេញពីការប្រែប្រួលថ្លៃ (change in price level) និងការប្រែប្រួលជាបរិមាណ (other change in the volume) ទ្រព្យសកម្ម ឬបំណុលឡើយ។ គោលនយោបាយរបស់រដ្ឋាភិបាលមានឥទ្ធិពលផ្ទាល់លើប្រតិបត្តិការដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យប្រែប្រួល ព្រោះតែរដ្ឋាភិបាលជាអ្នកគ្រប់គ្រងដោយផ្ទាល់លើសេចក្តីសម្រេចចិត្តចំពោះគ្រប់ប្រតិបត្តិការទាំងអស់។ ចំណេញ ឬខាតចេញពីការប្រែប្រួលតម្លៃសុទ្ធនៃទ្រព្យសកម្ម ឬបំណុល (ប្រែប្រួលថ្លៃទីផ្សារ) និងការប្រែប្រួលជាបរិមាណ (ដោយសារព្រឹត្តិការណ៍ណាមួយ) គឺមិនស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់រដ្ឋាភិបាលឡើយ តែរដ្ឋាភិបាលអាចមានយន្តការ ឬគោលនយោបាយដើម្បីកាត់បន្ថយផលប៉ះពាល់ដែលកើតចេញពីការប្រែប្រួលខាងលើឱ្យស្ថិតក្នុងកម្រិតអប្បបរមា។

២.៤. សមតុល្យនៃការផ្តល់កម្ចី ឬការទទួលកម្ចី ដែលបង្ហាញឱ្យឃើញពីការប្រើប្រាស់ (វិនិយោគ) ធនធានហិរញ្ញវត្ថុសម្រាប់ សេដ្ឋកិច្ចក្នុងប្រទេស ឬក្រៅប្រទេស (ការឱ្យខ្ចី) ឬបង្ហាញឱ្យឃើញពីការទាញយកអត្ថប្រយោជន៍ប្រភពហិរញ្ញប្បទានពី វិស័យខាងក្រៅទាំងសេដ្ឋកិច្ចក្នុងប្រទេស ឬក្រៅប្រទេស (ប្រាក់កម្ចី)។ តុល្យភាពនេះជាសូចនាករមួយដែលបង្ហាញឱ្យឃើញពីឥទ្ធិពលនៃសកម្មភាពហិរញ្ញវត្ថុរបស់រដ្ឋាភិបាលទៅលើសេដ្ឋកិច្ចទាំងក្នុង និងក្រៅប្រទេស។

២.៥. តុល្យភាពប្រតិបត្តិការដុល មានភាពខុសគ្នាពីតុល្យភាពប្រតិបត្តិការសុទ្ធនៅត្រង់ថាតុល្យភាពប្រតិបត្តិការដុលមិនបានរួមបញ្ចូលនូវចំណាយលើការប្រើប្រាស់ (ឬរំលោះ) ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុឡើយ។ ប្រសិនបើតុល្យភាពប្រតិបត្តិការដុលធំជាងតុល្យភាពប្រតិបត្តិការសុទ្ធនេះមានន័យថាចំណាយលើការប្រើប្រាស់លើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុត្រូវបានកត់ត្រា។

២.៦. ចំណាយសរុប (Total expenditure) គឺជាលទ្ធផលដែលបានមកពីចំណាយ (expenses) និងវិនិយោគ (ការទិញ/ដោះដូរ) លើទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ។ ចំណាយសរុបនេះបានរួមបញ្ចូលទាំងចំណាយលើការប្រើប្រាស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុមានភាពសមស្របសម្រាប់ការប្រៀបធៀបជាមួយបណ្តាប្រទេសផ្សេងៗ បើទោះបីជាការវាយតម្លៃចំណាយរំលោះនៅមិនទាន់មានសង្គតិភាពនៅឡើយក៏ដោយ។

២.៧. ចំណូល គឺជាប្រតិបត្តិការ (transaction) ដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យកើនឡើង។ ធាតុសំខាន់ៗនៃចំណូលរួមមាន៖ ចំណូលពន្ធ (កូដលេខ ១១), ចំណូលពីការចូលរួមសង្គម (កូដលេខ ១២), ចំណូលពីអំណោយ (កូដលេខ ១៣), និងចំណូលផ្សេងៗ (កូដលេខ ១៤)។ ចំណូលដែលបានមកពីការលក់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលប្រើប្រាស់រួច(ជម្រះបញ្ជី) មិនត្រូវបានទទួលស្គាល់ជាចំណូលឡើយ ពីព្រោះវាមិនបានធ្វើឱ្យមានការប្រែប្រួលតម្លៃសុទ្ធនៃទ្រព្យសកម្មនោះទេ។ អ្វីដែលប្រែប្រួលចេញពីប្រតិបត្តិការនេះគឺ ការប្រែប្រួលសមាសធាតុដែលមាននៅក្នុងតារាងតុល្យភាពតែប៉ុណ្ណោះ ពោលគឺទ្រព្យសកម្មមួយថយចុះ (ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ)ហើយទ្រព្យសកម្មផ្សេងកើនឡើង (សាច់ប្រាក់)។ ដូចគ្នាដែរសម្រាប់ប្រាក់កម្ចីដែលទទួល បាន ឬការសងបំណុលដែលគេជំពាក់ក៏មិនត្រូវបានចាត់ទុកជាចំណូលដែរ។

២.៨. ចំណាយ គឺជាប្រតិបត្តិការ (transaction) ដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យថយចុះ។ ធាតុសំខាន់ៗនៃចំណាយរួមមាន៖ ចំណាយប្រាក់បៀវត្ស និងលាភការ (២១), ចំណាយការប្រើប្រាស់ទំនិញ និងសេវាកម្ម (២២), ចំណាយលើការប្រាក់ (២៤),ចំណាយលើការឧបត្ថម្ភធន (២៥), ចំណាយលើអំណោយ (២៦) ចំណាយលើឧបត្ថម្ភសង្គមកិច្ច (២៧), និងចំណាយផ្សេងៗ (២៨)។ មិនត្រឹមតែប៉ុណ្ណោះ ចំណាយក៏ត្រូវបានធ្វើចំណាត់ថ្នាក់ទៅតាមមុខងាររបស់រដ្ឋាភិបាលផងដែរដូចជា៖ ចំណាយលើសុខភាព ឬកិច្ចការពារសង្គមជាដើម។ ការទិញ ឬដោះដូរទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ មិនត្រូវបានចាត់ទុកជាចំណាយឡើយ ពីព្រោះវាមិនបានធ្វើឱ្យមានការប្រែប្រួលតម្លៃសុទ្ធនៃទ្រព្យឡើយ។ ការប្រែប្រួលកើតចេញពីប្រតិបត្តិការខាងលើនេះគឺការប្រែប្រួលសមាសធាតុដែលមាននៅក្នុងតារាងតុល្យភាពតែប៉ុណ្ណោះ។ ដូចគ្នាដែរសម្រាប់ប្រាក់កម្ចីដែលបានសងក៏មិនត្រូវបានចាត់ទុកជាចំណាយដែរ។

២.៩. ផ្នែកទី៣ នៃតារាងស្ថិតិប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាលនេះគឺជា **ប្រតិបត្តិការហិរញ្ញវត្ថុ** ទាំងឡាយដែលធ្វើឱ្យមានបម្រែបម្រួលទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុល។ ប្រតិបត្តិការហិរញ្ញវត្ថុត្រូវបានធ្វើចំណាត់ថ្នាក់ដោយផ្អែកលើដៃគូ (counterpart) ដែលបានជំពាក់ (ទាំងក្នុង និងក្រៅប្រទេស) ទាំងក្នុងទ្រព្យសកម្ម និងបំណុល។

២.១០. បន្ថែមលើចំណាត់ថ្នាក់ខាងលើ ប្រតិបត្តិការទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលក៏ត្រូវបានធ្វើចំណាត់ថ្នាក់ដោយផ្អែកលើប្រភេទឧបករណ៍ហិរញ្ញវត្ថុដែលមានដូចជា៖ រូបិយវត្ថុ មាស និងអេសឌីអា, រូបិយប័ណ្ណ និងប្រាក់បញ្ញើ, មូលបត្របំណុល, កម្ចី, ដើមទុន និងមូលនិធិភាគហ៊ុន, ធានារ៉ាប់រង សោធន និងកញ្ចប់ធានារ៉ាប់រង, ដេរីវេទីវហិរញ្ញវត្ថុ និងភាគហ៊ុនបុគ្គលិក, គណនីត្រូវទទួល/ត្រូវសងផ្សេងៗ។ មិនត្រឹមតែប៉ុណ្ណោះប្រតិបត្តិការទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលក៏ត្រូវបានធ្វើចំណាត់ថ្នាក់ដោយផ្អែកលើវិស័យដែលជាដៃគូបដិភាគនៃឧបករណ៍ហិរញ្ញវត្ថុដូចជា៖ សាជីវកម្មហិរញ្ញវត្ថុ, សាជីវកម្មមិនមែនហិរញ្ញវត្ថុ, គេហកិច្ច (household) និងស្ថាប័នមិនស្វែងរកប្រាក់ចំណេញ។

២.១១. មធ្យោបាយម្យ៉ាងទៀតនៃការធ្វើចំណាត់ថ្នាក់ប្រតិបត្តិការទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុល គឺដោយផ្អែកលើការកើនឡើងថ្មី ឬក៏ការជម្រះចេញ ដែលបម្រើឱ្យគោលដៅនយោបាយ ឬក៏ផ្អែកលើការគ្រប់គ្រងសន្ទនីយភាព។ ភាពខុសគ្នានោះនៅត្រង់ថាវាមិនត្រូវបានរាប់បញ្ចូលក្នុងតារាងស្ថិតិប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋាភិបាលទេ តែវាត្រូវប្រើសម្រាប់កំណត់តុល្យភាពសារពើពន្ធ។

២.១២. គោលនយោបាយសាធារណៈដែលទាក់ទងទៅនឹងទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលអាចត្រូវបានលើកមកគិតគូរក្នុងហេតុផលផ្សេងៗ ដូចជាការជំរុញឧស្សាហកម្មថ្មី, ជួយសង្គ្រោះសាជីវកម្មសាធារណៈ, ឬក៏ជួយអាជីវកម្មណាមួយដើម្បីឱ្យមានភាពសម្បូរបែបក្នុងសេដ្ឋកិច្ច។ ប្រតិបត្តិការទាំងនេះអាចមានទម្រង់ផ្សេងៗគ្នាដូចជា៖ កម្ចី, មូលបត្រដើមទុន ឬមូលបត្របំណុលជាដើម។ ជាមួយគ្នានេះដែរ ប្រតិបត្តិការខាងលើក៏អាចមានផងដែរក្នុងទម្រង់ជាសម្បទាន។

២.១៣. ប្រតិបត្តិការទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗទៀត គឺត្រូវបានសន្មត់ថាជាការគ្រប់គ្រងសន្ទនីយភាពឬក៏គោលបំណងផ្សេង ដែលនេះបង្ហាញថាទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានគ្រប់គ្រងដោយបានទាញយកផលប្រយោជន៍ស្របតាមអត្រាទីផ្សារ ព្រមទាំងធានាបាននូវមូលនិធិគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការប្រចាំថ្ងៃ ឬគ្រប់គ្រាន់ជាមួយតម្រូវការសង្គមនៅពេលខាងមុខដូចជាមូលនិធិពិសេសរបស់រដ្ឋាភិបាលជាដើម។

៣.ភាពខុសគ្នារវាងស្ថិតិ GFSM1986 (**ឬស្ថិតិ** TOFE) **និងស្ថិតិ** GFSM2014

៣.១. នៅអំឡុងដើមឆ្នាំ១៩៧០ វិធីសាស្ត្រចងក្រងស្ថិតិអនុលោមតាមស្តង់ដារអន្តរជាតិបានវិវត្តជាបន្តបន្ទាប់ ដោយមានសេចក្តីព្រាងលើសៀវភៅណែនាំស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលជាបន្ទាត់នៃកិច្ចចាប់ផ្តើម។ ជាលទ្ធផល សៀវភៅណែនាំ GFM1986 ត្រូវបានបោះពុម្ពផ្សាយ ក្នុងគោលដៅផ្តល់គោលការណ៍ណែនាំផ្សេងៗ សម្រាប់គាំទ្រដល់ដំណើរការចងក្រងស្ថិតិនេះ ប៉ុន្តែពុំទាន់មានលទ្ធភាពអាចបំពេញនូវតម្រូវការនៃការប្រើប្រាស់ឱ្យបានពេញលេញឡើយ រីឯសូចនាករក្នុងក្របខណ្ឌស្ថិតិនេះ ក៏ពុំទាន់ស្របជាមួយក្របខណ្ឌនៃប្រព័ន្ធស្ថិតិម៉ាក្រូសេដ្ឋកិច្ចផ្សេងទៀតទេ។ ដោយមើលឃើញពីសារៈសំខាន់នៃការប្រើប្រាស់ស្ថិតិសម្រាប់គាំទ្រដល់ការវិភាគគោលនយោបាយសារពើពន្ធ សៀវភៅណែនាំ GFM2001 ត្រូវបានបោះផ្សាយ ក្នុងគោលដៅកែលម្អលើសៀវភៅណែនាំចាស់ (GFSM1986), ពង្រឹងភាពបន្សុីគ្នារវាងក្របខណ្ឌនៃប្រព័ន្ធស្ថិតិម៉ាក្រូសេដ្ឋកិច្ច, និងកែលម្អក្របខណ្ឌ និងរចនាសម្ព័ន្ធស្ថិតិក្នុងគោលដៅផ្តល់នូវសូចនាករដែលអាចគាំទ្រដល់ការវិភាគគោលនយោបាយសារពើពន្ធបាន។

៣.២. សៀវភៅណែនាំ GFSM2014 គឺជាសៀវភៅណែនាំចុងក្រោយគេបង្អស់របស់ប្រព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល ដែលក្នុងនោះបានបញ្ចូលបន្ថែមនូវគោលការណ៍ណែនាំថ្មីៗដែលមានការទទួលស្គាល់ជាអន្តរជាតិសម្រាប់ការចងក្រងស្ថិតិសារពើពន្ធ។ ប្រព័ន្ធស្ថិតិ GFSM2014 ថ្មីនេះ មានភាពសុីសង្វាក់គ្នាជាមួយនឹងក្របខណ្ឌនៃស្ថិតិដទៃទៀតក្នុងប្រព័ន្ធស្ថិតិម៉ាក្រូសេដ្ឋកិច្ច រួមមាន ប្រព័ន្ធគណនេយ្យជាតិឆ្នាំ២០០៨ (SNA2008), ស្ថិតិជញ្ជីងទូទាត់ បោះពុម្ពលើកទី៦ (BPM6), និងស្ថិតិរូបិយវត្ថុនិងហិរញ្ញវត្ថុឆ្នាំ២០១៦ (MFSM)។

៣.៣. ស្របតាមការប្រែប្រួលជាសកលនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងភាពស្មុគស្មាញនៃសកលភាវូបនីយកម្ម ការរៀបចំគោលនយោបាយសេដ្ឋកិច្ច តម្រូវឱ្យមានការរៀបចំស្ថិតិមួយដែលអាចឆ្លើយតបការវិភាគ ពោលគឺស្ថិតិដែលមានន័យសេដ្ឋកិច្ចគ្រប់គ្រាន់ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ និងអាចប្រៀបធៀបជាសកលបាន។ ក្នុងន័យនេះ ប្រព័ន្ធស្ថិតិ GFSM2014 ត្រូវបានកែលម្អក្នុងគោលបំណងពង្រឹងគុណភាពកិច្ចបញ្ជិកាប្រតិបត្តិការនានា និងការធ្វើចំណាត់ថ្នាក់ស្ថិតិឱ្យបានត្រឹមត្រូវ ជាពិសេសឆ្លុះបញ្ចាំងពីសកម្មភាពសេដ្ឋកិច្ចជាក់ស្តែង តាមរយៈការបន្សុីស្តង់ដារគណនេយ្យសាធារណៈ (IPSAS) ជាមួយនឹងប្រព័ន្ធស្ថិតិ និងបង្កើនភាពសុីចង្វាក់គ្នារវាងរបាយការណ៍ស្ថិតិ (statistical reporting) និងរបាយការណ៍ហិរញ្ញវត្ថុ (financial reporting)។

៣.៤. ដូចបានរៀបរាប់ក្នុងចំណុច ២.៧ ខាងលើ, ចំណូល គឺជាប្រតិបត្តិការ (transaction) ដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យកើនឡើង។ ជាក់ស្តែង ផ្អែកតាមសៀវភៅណែនាំ GFSM2014 ប្រតិបត្តិការចំណូល គឺជាប្រតិបត្តិការដែលធ្វើឱ្យទ្រព្យសកម្មកើនឡើង ឬបំណុលថយចុះ ពោលគឺធ្វើឱ្យទ្រព្យសុទ្ធ (net worth) កើនឡើង។ ទន្ទឹមនេះ ចំណាយ គឺជាប្រតិបត្តិការ (transaction) ដែលធ្វើឱ្យតម្លៃសុទ្ធនៃទ្រព្យថយចុះ។ ក្នុងប្រព័ន្ធស្ថិតិ GFSM2014 ចំណាយសរុប (expenditure) ស្មើនឹងចំណាយ (លេខកូដ ២) បូកជាមួយនឹងទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ (លេខកូដ ៣១) ដែលប្រតិបត្តិការចំណាយនេះទៀតសោត ធ្វើឱ្យទ្រព្យសកម្មថយចុះ ឬបំណុលកើនឡើង ពោលគឺធ្វើឱ្យទ្រព្យសុទ្ធ (net worth) ថយចុះ។

៣.៥. ក្នុងប្រព័ន្ធស្ថិតិ GFSM2014 ការធ្វើចំណាត់ថ្នាក់ស្ថិតិ គឺកើតមានចំពោះតែប្រតិបត្តិការដែលមានសកម្មភាព ឬឥទ្ធិពលក្នុងការបង្កើន ឬបន្ថយទ្រព្យសុទ្ធរបស់រាជរដ្ឋាភិបាល, ឬមានលក្ខណៈអាចបង្កើតឱ្យមានសកម្មភាព ឬតម្លៃសេដ្ឋកិច្ចបាន, ប៉ុន្តែក្នុងប្រព័ន្ធស្ថិតិ GFSM1986 វិញ រាល់ប្រតិបត្តិការទាំងអស់ដែលបង្កឱ្យបង្កើន ឬបន្ថយសាច់ប្រាក់ ត្រូវបានចាត់ថ្នាក់ជាចំណូល និងចំណាយ ទោះជាមិនបង្កឱ្យមានសកម្មភាពសេដ្ឋកិច្ចក៏ដោយ។ ជាឧទាហរណ៍ជាក់ស្តែង ប្រតិបត្តិការដូចជា **ចំណូលមូលធន, ចំណូលពីការបង្វិលសងវិញនូវពន្ធ និងអាករ**

ផ្សេងៗ, ចំណូលពីផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ, អំណោយទ្រទ្រង់ថវិកា, និងអំណោយ ជាដើម, មានការធ្វើចំណាត់ថ្នាក់ផ្សេងពីគ្នាក្នុងប្រព័ន្ធទាំងពីរ។

៣.៦. ចំណូលមូលធន គឺជាប្រតិបត្តិការចំណូលដែលរាជរដ្ឋាភិបាលទទួលបានមកពីកម្ចី។ ក្នុងប្រព័ន្ធស្ថិតិ GFSM1986 ប្រតិបត្តិការនេះត្រូវបានកត់ត្រាជាចំណូលនៅពេលរាជរដ្ឋាភិបាលទទួលបានកម្ចី បន្ទាប់មក ត្រូវបានកត់ត្រាជាចំណាយនៅពេលរាជរដ្ឋាភិបាលសងបំណុលនោះ។ ដោយឡែក ក្នុងប្រព័ន្ធស្ថិតិ GFSM2014 វិញ ប្រតិបត្តិការនេះមិនត្រូវបានចាត់ថ្នាក់ជាប្រតិបត្តិការចំណូលឬចំណាយឡើយ ប៉ុន្តែត្រូវគណនារកប្រតិបត្តិការសុទ្ធ (net) ស្មើនឹង*ប្រាក់ដើមដកប្រាក់សង* រួចកត់ត្រាក្នុងបំណុលសុទ្ធ (net incurrence of liabilities) វិញ។

៣.៧. ចំណូលពីការបង្វិលសងវិញនូវពន្ធ និងអាករផ្សេងៗ គឺជាប្រតិបត្តិការទទួលបានពីការបង់ពន្ធលើសបរិមាណដែលអ្នកជាប់ពន្ធត្រូវបង់។ ក្នុងប្រព័ន្ធស្ថិតិ GFSM1986 ប្រតិបត្តិការនេះ ត្រូវបានកត់ត្រាជាចំណូលពន្ធ បន្ទាប់មក កត់ត្រាជាចំណាយចរន្តនៅពេលបង្វិលសងបរិមាណដែលលើសនោះទៅអ្នកជាប់ពន្ធវិញ។ ដោយឡែក ក្នុងប្រព័ន្ធស្ថិតិ GFSM2014 ប្រតិបត្តិការនេះមិនបានចាត់ថ្នាក់ជាចំណូលឬចំណាយឡើយ ពោលគឺធ្វើចំណាត់ថ្នាក់គណនាចំណូលពន្ធសុទ្ធ (netting the refund)។

៣.៨. ចំណូលពីផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ សំដៅដល់រាល់ប្រតិបត្តិការទទួលបានពីការលក់ ឬរំលោះចោលនូវទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់អង្គភាព ឬស្ថាប័ន។ ក្នុងន័យនេះ ប្រព័ន្ធស្ថិតិ GFSM1986 ទទួលស្គាល់ប្រតិបត្តិការនេះជាចំណូល ស្របពេល ប្រព័ន្ធស្ថិតិ GFSM2014 ទទួលស្គាល់ប្រតិបត្តិការនេះជាទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ។

៣.៩. អំណោយទ្រទ្រង់ថវិកា និងអំណោយ ជាជំនួយថវិកាទទួលបានពីជំនួយទ្វេភាគី និងពហុភាគីសម្រាប់ប្រើប្រាស់លើចំណាយវិនិយោគ។ ក្នុងន័យនេះ ប្រព័ន្ធស្ថិតិ GFSM1986 ចាត់ថ្នាក់ប្រតិបត្តិការនេះ ជាហិរញ្ញប្បទានបរទេស ខណៈពេលប្រព័ន្ធស្ថិតិ GFSM2014 ចាត់ថ្នាក់ប្រតិបត្តិការនេះ ជាចំណូលឧបត្ថម្ភពីរដ្ឋាភិបាលបរទេស និងចំណូលឧបត្ថម្ភពីអង្គការអន្តរជាតិ។

៤. ការប្រើប្រាស់ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលសម្រាប់ការវិភាគសារពើពន្ធ

៤.១. ប្រព័ន្ធស្ថិតិ GFSM2014 ចូលរួមចំណែកក្នុងការពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការផ្តល់នូវព័ត៌មានហិរញ្ញវត្ថុសាធារណៈ (ការប្រមូលចំណូល, ការបែងចែកចំណាយ, ការវិនិយោគ, ការគ្រប់គ្រងនិងប្រើប្រាស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុល)ក្នុងទម្រង់ស្ថិតិអនុលោមតាមនិយាមអន្តរជាតិ សម្រាប់គាំទ្រដល់ការពិនិត្យ តាមដាន និងវាយតម្លៃប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងនិរន្តរភាពសារពើពន្ធរយៈពេលវែង។

៤.២. គោលនយោបាយសារពើពន្ធរបស់ប្រទេសមួយ ពុំមាននិរន្តរភាពនោះទេ ប្រសិនបើវាធ្វើឱ្យតម្លៃសុទ្ធរបស់រាជរដ្ឋាភិបាលថយចុះខ្លាំង។ ដូច្នេះ ការរក្សាតម្លៃសុទ្ធរបស់រដ្ឋាភិបាល បានក្លាយជាមូលដ្ឋានសំខាន់ក្នុងវិធីសាស្ត្រធ្វើចំណាត់ថ្នាក់ស្ថិតិលើប្រតិបត្តិការនីមួយៗ ឱ្យសមស្របតាមតថភាពសេដ្ឋកិច្ចជាក់ស្តែង។ ក្នុងន័យនេះ ប្រព័ន្ធស្ថិតិ GFS ទទួលស្គាល់តែប្រតិបត្តិការចំណូល និង/ ឬចំណាយណា ដែលមានលទ្ធភាពអាចបង្កើន ឬបន្ថយតម្លៃសុទ្ធស្របតាមសកម្មភាពសេដ្ឋកិច្ចកើតមាន។ ទន្ទឹមនេះ ប្រតិបត្តិការផ្សេងទៀតដូចជា ការវិនិយោគសុទ្ធ (ការទិញដកការលក់) នៃទ្រព្យសកម្ម, បំណុលសុទ្ធ (បំណុលដកសំណង) -ល-, គឺជាប្រតិបត្តិការដែលមិនប៉ះពាល់ដល់តម្លៃសុទ្ធឡើយ ពោលគឺធ្វើឱ្យមានបម្រែបម្រួលទ្រព្យសកម្ម និងបំណុលរបស់រាជរដ្ឋាភិបាលតែប៉ុណ្ណោះ។

៤.៣. ប្រព័ន្ធថវិកា និងស្តង់ដារគណនេយ្យរបស់រាជរដ្ឋាភិបាល គឺអនុលោមស្របតាមក្របខណ្ឌ និងគោលការណ៍របស់ប្រទេសនីមួយៗ ដែលពុំមានសង្គតិភាពជាមួយនឹងប្រព័ន្ធស្ថិតិម៉ាក្រូសេដ្ឋកិច្ចឡើយ ពោលគឺមានទម្រង់បែបបទរាយការណ៍ផ្សេងៗគ្នា។ ក្នុងន័យនេះ ប្រព័ន្ធស្ថិតិ GFSM2014 ដើរតួជាស្ពានចម្លងរវាងស្តង់ដារជាតិ (national standard) ជាមួយនឹងស្តង់ដារដែលអាចប្រៀបធៀបបានជាអន្តរជាតិ (internationally comparable framework)។

៤.៤. ប្រព័ន្ធស្ថិតិ GFS អាចផ្តល់នូវសូចនាករសារពើពន្ធ (fiscal indicators) មួយចំនួន រួមមានទាំងប្រតិបត្តិការរំហូរ, រំហូរសេដ្ឋកិច្ចផ្សេងៗ, ទិន្នន័យសន្និធិ, -ល- ដែលអាចគាំទ្រដល់ការតាមដាន, វាយតម្លៃ, វិភាគ និងរៀបចំគោលនយោបាយសារពើពន្ធ។ សូចនាករសារពើពន្ធមួយចំនួន ដូចជា (១). សមតុល្យសារពើពន្ធ (fiscal balances), (២). សូចនាករសារពើពន្ធម៉ាក្រូសេដ្ឋកិច្ចផ្សេងទៀត (other macroeconomic fiscal indicators), (៣). សូចនាករហិរញ្ញប្បទាន (financing indicators), និង (៤). សូចនាករទ្រព្យសម្បត្តិនិងបំណុល (wealth and debt indicators) អាចទាញយកដោយផ្ទាល់ពីប្រព័ន្ធស្ថិតិ GFS ប៉ុន្តែសូចនាករផ្សេងទៀត ទាមទារឱ្យមានការគណនាបន្ថែមជាមួយនឹងទិន្នន័យនៃប្រព័ន្ធម៉ាក្រូសេដ្ឋកិច្ចផ្សេងទៀត៕

៨.កំណត់សម្គាល់ស្ថិតិ

តារាងស្ថិតិឆ្នាំ ២០២៣

វិធីសាស្ត្រស្ថិតិ : ផ្អែកលើសៀវភៅណែនាំស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាលឆ្នាំ២០១៤ (GFSM2014)

ឯកតា : គិតជាលានរៀល

វិសាលភាពស្ថាប័ន : ផ្អែកលើកម្រិតរដ្ឋបាលរួមមាន÷

កម្រិតទី១÷	រដ្ឋបាលថ្នាក់ជាតិមិនរួមបញ្ចូលគ្រឹះស្ថានសាធារណៈរដ្ឋបាល	បានផ្សព្វផ្សាយ និងធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣
កម្រិតទី២÷	រដ្ឋបាលថ្នាក់ជាតិ	ទិន្នន័យបានរៀបចំ និងអាចផ្តល់ជូនតាមការស្នើសុំ
កម្រិតទី៣÷	រដ្ឋបាលថ្នាក់ក្រោមជាតិទាំង ៣ កម្រិត	បានផ្សព្វផ្សាយ និងធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣
កម្រិតទី៤÷	រដ្ឋាភិបាលទាំងមូល (កម្រិតទី១ + កម្រិតទី៣)	បានផ្សព្វផ្សាយ និងធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣
កម្រិតទី៥÷	រដ្ឋាភិបាលទាំងមូល (កម្រិតទី២ + កម្រិតទី៣)	ទិន្នន័យបានរៀបចំ និងអាចផ្តល់ជូនតាមការស្នើសុំ
កម្រិតទី៦÷	កម្រិតទី៥ + វិស័យសាជីវកម្មសាធារណៈមានលក្ខណៈមិនមែនហិរញ្ញវត្ថុ	ទិន្នន័យពុំទាន់រៀបចំ
កម្រិតទី៧÷	កម្រិតទី៦ + វិស័យសាជីវកម្មសាធារណៈមានលក្ខណៈហិរញ្ញវត្ថុ	ទិន្នន័យពុំទាន់រៀបចំ

Reference: ***Government Finance Statistics Manual 2014 (GFSM 2014)***